**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ នៃក្រសួងសាធារណការនិងដឹកជញ្ជូន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានសាធារណការនិងសំណង់នៃក្រសួងសាធារណការនិងដឹកជញ្ជូន មានឋានៈស្មើនាយកដ្ឋាន បំពេញបន្ថែមអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។

**មាត្រា២ .-**

មជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- អន្តរាគមន៍ជាបន្ទាន់ការងារជួសជុលស្ពាន-ថ្នល់ និង លូ
- គ្រប់គ្រងនិងថែទាំគ្រឿងចក្រនិងគ្រឿងបរិក្ខារផ្សេងៗរបស់អង្គភាពអោយបានល្អ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារ ជូនអគ្គនាយកដ្ឋានសាធារណការនិងសំណង់
- ជួសជុលនិងថែទាំស្ពាន-ថ្នល់ និង លូ គ្រប់ប្រភេទនៅតាមបណ្តោយផ្លូវជាតិនិងផ្លូវខេត្ត
- ត្រួតពិនិត្យស្ថានភាពស្ពាន-ថ្នល់និងលូ និង ចងក្រងឯកសារបញ្ជូនមកអគ្គនាយកដ្ឋានសាធារណការនិងសំណង់
- រៀបចំផែនការឆ្នាំនិងទំនាក់ទំនងរកជំនួយសម្រាប់ការងារថែទាំ ជួសជុល ស្តាបនាស្ពាន-ថ្នល់ និង លូ មកអនុវត្តផ្ទាល់
- ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសសាងសង់ ជួសជុល ថែទាំស្ពាន-ថ្នល់ និង លូ
- ធ្វើការបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសសាងសង់ ជួសជុលថ្មីៗដល់អង្គភាពក្រោមឱវាទនិងអង្គភាពពាក់ព័ន្ធផ្សេងទៀត
- ទទួលភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន

**មាត្រា៣ .-**

មជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

មជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ មានអង្គភាព ឬ ការិយាល័យជំនាញមួយចំនួនត្រូវបំបែកចេញពីនាយកដ្ឋានផ្លូវថ្នល់នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជួសជុលនិងថែទាំផ្លូវ-ថ្នល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ